# ម៉ូឌុល ១: ទស្សនៈស្តីពី វិមជ្ឈការ



# ២ - អ្វីទៅជាវិមជ្ឈការ?



- ជាការផ្ទេរ**<u>អំណាច</u>** និង**ការទទួលខុសត្រូវ** ចំពោះ**មុខងារសាធារណៈ**ពីសំណាក់រដ្ឋាភិបាលថ្នាក់កណ្តាល/ជាតិ ទៅដល់រដ្ឋាភិបាលបាលថ្នាក់ទាបជាង និងរដ្ឋាភិបាលមូលដ្ឋាន ឬអង្គភាពឯករាជ្យរបស់រដ្ឋាភិបាល ឬក៏ទៅដល់វិស័យឯកជន។ Hans Bjørn Olsen, 2007, *Decentralisation And Local Governance, SDC*
- រាជរដ្ឋាភិបាល ប្រគល់នូវភាពជាម្ចាស់ លើមុខងារ សិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ឱ្យទៅក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ដូចជាក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាន។ NCDD, 2009, Manual for basic principles in sub national administration, p.3

# សេចក្ដីផ្ដើមអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ



| | |
|---|---|
| 2001 | អនុម័តច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ |
| 2002 | ការបោះឆ្នោតក្រុមប្រឹក្សាថ្នាក់ឃុំ/សង្កាត់លើកទី ១ |
| 2004 | យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ១ (២០០៤-២០០៨) |
| 2005 | ក្របខណ្ឌយុទ្ធសាស្រ្តសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ |
| 2006 | ផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិ (២០០៦-២០១០) |

2007

ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់លើកទី ២

2008

- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ (២០០៨-២០១២)
- អនុម័តច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

2009

- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០០៩-២០១៣
- ការបោះឆ្នោតក្រុមប្រឹក្សាថ្នាក់ក្រោមជាតិលើកទី ១

2010-

- កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD)
- ផែនការអនុវត្តកម្មវិធីជាតិ៣ ឆ្នាំដំបូង

# តើវិមជ្ឈការក្នុងបរិបទកម្ពុជាមានលក្ខណៈយ៉ាងដូចម្ដេច?



| | |
|---|---|
| **វិមជ្ឈការ**<br>Decentralization | ក្រសួងផ្ទេរមុខងារ និងធនធានមួយចំនួនដល់ក្រុមប្រឹក្សា នៅថ្នាក់ក្រោមជាតិបំពេញ ជំនួសដែលមុខងារទាំងនោះជាមុខងារ ផ្ទាល់របស់ក្រុមប្រឹក្សាដែលអនុលោមតាម រដ្ឋធម្មនុញ្ញ និងលិខិតបទដ្ឋាននានា |
| **ប្រតិភូកម្ម**<br>Delegation | ក្រសួងផ្ទេរមុខងារ និងធនធានមួយចំនួនដល់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិបំពេញជំនួសដែលមុខងារទាំងនោះនៅតែជាមុខងាររបស់ក្រសួងដែលក្រសួងជាអ្នកណែនាំ លំអិតអំពីរបៀបអនុវត្ត |
| **វិសហមជ្ឈការ**<br>De-concentration | ក្រសួងប្រគល់ភារកិច្ចដល់រចនាសម្ព័ន្ធ នៅថ្នាក់ក្រោមជាតិរបស់ក្រសួងដើម្បីអនុវត្តភារកិច្ចជំនួស អ្នកអនុវត្តជាបុគ្គលិកជាខ្សែបណ្ដោយរបស់ក្រសួងហើយក្រសួងជាអ្នកណែនាំលំអិតអំពីរបៀបអនុវត្តមុខងារ |

# រដ្ឋាភិបាលថ្នាក់ជាតិ

ផ្ទេរធនធាន

ការទទួលខុសត្រូវ

- រដ្ឋបាល និងភ្នាក់រដ្ឋដែលមាន កម្រិតទាបជាង
- ក្រុមហ៊ុនឯកជន
- អង្គភាពពាក់កណ្តាលស្វ័យត

## ៣_ប្រភេទនៃវិមជ្ឈការ

## មុខងារសាធារណៈ

### នយោបាយ

រៀបចំឱ្យមានការបោះឆ្នោតជ្រើសរើសតំណាងនៅថ្នាក់មូលដ្ឋាន

### សេដ្ឋកិច្ច

- ការកាត់បន្ថយការត្រួតត្រារបស់រដ្ឋាភិបាល
- ឯកជនភាវូបនីយកម្ម

### សារពើពន្ធ

- ការរកចំណូល និងបដិភាគ/វិភាជថវិកា
- ការចំណាយ

### រដ្ឋបាល

- ប្រតិភូកម្ម
- វិសហមជ្ឈការ
- ការផ្ទេរសិទ្ធិអំណាចទាំងស្រុង

# ៣-ប្រភេទនៃវិមជ្ឈការ —ត-



| ទម្រង់វិមជ្ឈការ | និយមន័យ |
| --- | --- |
| **នយោបាយ** | គឺជាការផ្ទេរអំណាចនយោបាយ និងសិទ្ធិក្នុងការសំរេចចិត្តទៅដល់ថ្នាក់ក្រោមជាតិ។ |
| **រដ្ឋបាល** | ការផ្ទេរទាំងស្រុង ឬផ្នែកណាមួយនៃសិទ្ធិអំណាចក្នុងការសម្រេចចិត្ត ធនធាន និងការទទួលខុសត្រូវសម្រាប់ផ្តល់សេវាសាធារណៈទៅកាន់រដ្ឋាភិបាល ភ្នាក់ងាររបស់រដ្ឋដែលមានកម្រិតទាបជាង។ |
| **សារពើពន្ធ** | ពាក់ព័ន្ធទៅនឹងការផ្ទេរសិទ្ធិដល់រដ្ឋាភិបាលមូលដ្ឋាន ក្នុងការចាត់ចែងកិច្ចការ ចំណាយ-ចំណូលដើម្បីឱ្យរដ្ឋាភិបាលមូលដ្ឋានបំពេញមុខងារមួយចំនួនដែលត្រូវបានផ្ទេរវិមជ្ឈការ |
| **សេដ្ឋកិច្ច** | វិមជ្ឈការសេដ្ឋកិច្ច ឬវិមជ្ឈការទីផ្សារ គឺជាការផ្ទេរនូវមុខងារដែលបំពេញផ្ដាច់មុខដោយរដ្ឋាភិបាលទៅឱ្យវិស័យឯកជន។ |

# វិមជ្ឈការរដ្ឋបាល



វិមជ្ឈការរដ្ឋបាលមានបីប្រភេទ:

| វិសហមជ្ឈការ | ប្រតិភូកម្ម | ការផ្ទេរសិទ្ធិទាំងស្រុង |
|---|---|---|
| ❑ មានការផ្ទេរសិទ្ធិអំណាចដល់នាយកដ្ឋានរដ្ឋបាលមួយ របស់រដ្ឋាភិបាលថ្នាក់កណ្តាល ឬក្នុងតំបន់ណាមួយ<br>❑ មន្ត្រីក្នុងមូលដ្ឋានត្រូវបានតែងតាំង | ❖ ផ្ទេរការទទួលខុសត្រូវធ្វើសេចក្តីសម្រេចចិត្ត និងកិច្ចការរដ្ឋបាលនៃមុខងារសាធារណៈទៅឱ្យអង្គការពាក់កណ្តាលស្វ័យភាព<br>❖ មាននេយ្យភាពចំពោះថ្នាក់ជាតិ។ | ■ មានការផ្ទេរការទទួលខុសត្រូវលើការផ្តល់សេវាកម្ម<br>■ មានសិទ្ធិរកចំណូលដោយខ្លួនឯង និងមានឯករាជភាពក្នុងការធ្វើសេចក្តីសម្រេចចិត្តលើផ្នែកវិនិយោគ<br>■ រដ្ឋាភិបាលមូលដ្ឋានមានព្រំប្រទល់ភូមិសាស្ត្រច្បាស់លាស់ និងទទួលស្គាល់ដោយច្បាប់ដែលអាចប្រើប្រាស់សិទ្ធិ អំណាចក្នុងការបំពេញមុខងារសាធារណៈ |

# វិមជ្ឈការសារពើពន្ធ

- ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង និងស្រុក (លើកលែងតែក្រុមប្រឹក្សាខណ្ឌ និងសង្កាត់ក្រោមរាជធានី និងក្រុង) មានសិទ្ធិទទួលបានចំណូលពី៖

  - **ចំណូលពីមូលដ្ឋាន** (ពន្ធឈ្នួល កម្រៃ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀត)

  - **ចំណូលពីថ្នាក់ជាតិ** (មូលនិធិផ្ទេរពីថវិការដ្ឋ ចំណូលចែករំលែកពីថវិការដ្ឋ និងថ្លៃសេវាបានមកពីការអនុវត្តមុខងារជាភ្នាក់ងារ) (ច្បាប់អង្គការ មាត្រា ២៤៦,២៤៧)

- ក្រុមប្រឹក្សាខណ្ឌ និង ក្រុមប្រឹក្សាសង្កាត់ ត្រូវមានថវិកាសម្រាប់អនុវត្តមុខងារ ភារកិច្ចរបស់ខ្លួន ដែលស្ថិតនៅក្នុងថវិការបស់រាជធានី និងថវិកាក្រុង។

វិមជ្ឈការសេដ្ឋកិច្ចមានពីរប្រភេទ:

| ឯកជនភាវូបនីយកម្ម (Privatization) | ការធ្វើនិយ័តកម្ម (Divestment/deregulation) |
|---|---|
| រដ្ឋាភិបាល និងវិស័យឯកជន សហការគ្នាក្នុងការផ្តល់សេវាកម្ម ឬហេដ្ឋារចនាសម្ព័ន្ធ។ | មានការកាត់បន្ថយការរឹតត្បិតផ្លូវច្បាប់ទៅលើវិស័យឯកជនក្នុងការផ្តល់សេវាកម្មដែលកន្លងមកជាសិទ្ធិផ្តាច់មុខរបស់រដ្ឋាភិបាល |